# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា

## ការិយាល័យអគ្គនាយកក្រសួងអប់រំ

**440 NORTH BROAD STREET, SUITE 301**
**PHILADELPHIA, PENNSYLVANIA 19130**

**WILLIAM R. HITE, JR., Ed.D.**
*អគ្គនាយកក្រសួងអប់រំ*


ថ្ងៃទី៧ ខែមករា ឆ្នាំ២០១៦

ជូនចំពោះ មាតាបិតា/អាណាព្យាបាល៖

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ាចេញ របាយការណ៍ស្តីពីការរីកចម្រើនរបស់សាលា (SPR) ជារៀងរាល់ឆ្នាំ ។ របាយការណ៍ស្តីពីការរីកចម្រើនរបស់សាលា ដូចគ្នានឹង «របាយការណ៍ពិន្ទុ» សម្រាប់សាលានីមួយៗ។ វាផ្តល់ព័ត៌មានអំពីជោគជ័យនៃការសិក្សារបស់សាលា ហើយត្រូវគេយកមកប្រើជាត្រីវិស្ស័យដើម្បីការកែលម្អសាលា។ របាយការណ៍ស្តីពីការរីកចម្រើនរបស់សាលា សម្រាប់ឆ្នាំសិក្សា ២០១៤-២០១៥ បានផ្សព្វផ្សាយនៅថ្ងៃនេះ។

របាយការណ៍ស្តីពីការរីកចម្រើនរបស់សាលា ផ្តល់ព័ត៌មានអំពី ចំណុចខ្លាំង និងចំណុចខ្សោយ របស់ក្រសួងអប់រំ និងសាលាឆាទ័រ។ វាជួយយើងក្នុងការតាមដានការរីកចម្រើនទៅកាន់គោលដៅរបស់យើង ដែលយើងចង់ឲ្យក្មេងអាយុប្រាំបីឆ្នាំ១០០ភាគរយ អាចអានបានតាមកម្រិតថ្នាក់ និងសិស្ស១០០ភាគរយបានត្រៀមខ្លួនជាស្រេចសម្រាប់មហាវិទ្យាល័យ និងអាជីព និងទៅកាន់គោលបំណងរបស់យើងដែលធ្វើយ៉ាងណាឲ្យក្មេងទាំងអស់មានសាលាល្អនៅជិតទីកន្លែងដែលពួកគេរស់នៅ។

របាយការណ៍ស្តីពីការរីកចម្រើនរបស់សាលា វាយតម្លៃសាលាក្នុងចំណុចច្រើនយ៉ាង រួមទាំង ជោគជ័យរបស់សិស្ស ការរីកចម្រើនរបស់សិស្ស សន្តិសុខសាលា និងការត្រៀមខ្លួនជាស្រេចសម្រាប់ វិទ្យាល័យ មហាវិទ្យាល័យ និង អាជីព។ សាលានីមួយៗត្រូវគេឲ្យចំណាត់ថ្នាក់តាមកម្រិតមួយ នៃកម្រិតបួន៖ គំរូ/Model (ខ្ពស់បំផុត) ពង្រឹង/Reinforce តាមដានមើល/Watch និង ធ្វើអន្តរាគមន៍/Intervene (ទាបបំផុត)។

បើមើលតាមលទ្ធផលនៃរបាយការណ៍ស្តីពីការរីកចម្រើនរបស់សាលាក្នុងឆ្នាំនេះ ខ្ញុំមានកម្លាំងចិត្តដោយឃើញការទទួលជោគជ័យរបស់សាលាមួយចំនួន និងការខិតខំប្រឹងប្រែងរបស់សាលាដទៃទៀត ក្នុងការកែលម្អការអប់រំ។ ទោះជាយ៉ាងនេះក្តី លទ្ធផលរបស់យើងក៏បង្ហាញឲ្យឃើញថា យើងត្រូវប្រឈមមុខតស៊ូនិងឧបស័គ្គនៅសាលាជាច្រើន ជាពិសេសសាលានៅក្នុងតំបន់របស់យើង។

នៅចុងខែនេះ ក្រសួងអប់រំនឹងចុះផ្សាយការណែនាំនៃ របាយការណ៍ស្តីពីការរីកចម្រើនរបស់សាលា សម្រាប់មាតាបិតា ដែលពន្យល់កាន់តែលម្អិតអំពីការបែងចែកកម្រិតខុសៗគ្នារបស់សាលា អ្វីៗដែលត្រូវបានគេយកមកថ្លឹងថ្លែង ហើយថាតើលទ្ធផលនៃរបាយការណ៍ស្តីពីការរីកចម្រើនរបស់សាលា ត្រូវដាក់ចូលទៅក្នុងផែនការនៃការកែលម្អសាលាដោយវិធីណា។

ដោយមានរបាយការណ៍ស្តីពីការរីកចម្រើនរបស់សាលា លោកអ្នកមានឱកាសដឹងព័ត៌មានអំពីការរីកចម្រើនរបស់សាលាលោកអ្នកកាន់តែច្រើន ដើម្បីតម្រូវតាមសេចក្តីត្រូវការរបស់កូនលោកអ្នក។ ខ្ញុំសង្ឃឹមថា លោកអ្នកនឹងប្រើ របាយការណ៍ស្តីពីការរីកចម្រើនរបស់សាលា ដើម្បីយល់ដឹង នឹងសួរសំណួរអំពីការអប់រំរបស់សាលាកូនលោកអ្នក។

ដោយសេចក្តីស្មោះស្ម័គ្រ



William R. Hite, Jr., Ed.D.